# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា អំពីព្រឹត្តិការណ៍កើតមាន នៅប្រទេសកម្ពុជា

**Website: www.hoksavann.org**

ថ្ងៃទី៣ តុលា ២០០៤

១- **អំពីកុន Hollywood Buddha អង្គុយលើព្រះកេសព្រះពុទ្ធរូប** ៖

ជំនឿរបស់មនុស្សមានកម្លាំងខ្លាំងក្លាណាស់ ដែលជាវប្បធម៌ដិតជាប់ក្នុងចិត្តគំនិតមនុស្ស ។ យ៉ាងណាមិញជំនឿរបស់ប្រជាជាតិខ្មែរក្នុងព្រះពុទ្ធសាសនា បានដិតជាប់ក្នុងចិត្តគំនិតខ្មែររាប់ពាន់ឆ្នាំមកហើយ បានរលាយជាសាច់ជាឈាមខ្មែរអស់ទៅហើយ ។ សម័យអាណានិគមនិយមបារាំង ខំព្យាយាមអូសទាញខ្មែរឲ្យឃ្លាតចេញពីព្រះពុទ្ធសាសនា ដោយយកសាសនាមួយទៀតមកដាក់ជំនួស តែពុំបានជោគជ័យឡើយ ។ សម័យកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) បានជីករំលើងឫសគល់ទាំងអស់របស់ព្រះពុទ្ធសាសនា ផ្ញើគត់និងផ្សឹកព្រះសង្ឃ បំបាត់គម្ពីរក្បួនច្បាប់ បំបាត់វត្តអារាម តែត្រូវទទួលបរាជ័យ មិនតែប៉ុណ្ណោះត្រូវប្រឈមមុខកាត់ទោសក្នុងតុលាការអន្តរជាតិថែមទៀត ។ នៅពេលដែលប្រជាពលរដ្ឋខ្មែរបានឃើញ និងបានដឹងនូវរូបភាពតួកុនហូល្លីវូដអង្គុយយ៉ាងសង្ហារលើព្រះកេសព្រះពុទ្ធរូបមក ធ្វើឲ្យចិត្តរបស់គេរន្ធត់យ៉ាងខ្លាំង រន្ធត់ដោយសារព្រះពុទ្ធរូបជាទីគោរព បានត្រូវតួកុននេះអង្គុយលើព្រះកេសធ្វើព្រងើយ ។ ប៉ុន្តែគួរឲ្យអាណិតអាសូរជនបាបនេះ ដែលហ៊ានប្រមាថមើលងាយបៀតបៀនសាសនាដទៃ ដោយភាពល្ងង់ខ្លៅរបស់ខ្លួន ។ អំពើរបស់តួកុននេះ ទោះបីធ្វើក្នុងមូលហេតុប្រឆាំងនឹងព្រះពុទ្ធសាសនាក្តី ឬដោយគោលបំណងពាណិជ្ជកម្ម ព្រោះបើយកព្រះរូបព្រះពុទ្ធមកដាក់ក្នុងកុនរបស់ខ្លួន ធ្វើឲ្យកុនខ្លួនល្បី និងទាញសាធារណជនឲ្យមើលច្រើនក្តី ចាត់ទុកថាជាអំពើប្រមាថមើលងាយអ្នកកាន់ពុទ្ធសាសនាដោយចេតនា ។ អំពើនេះមិនអាចធ្វើឲ្យព្រះពុទ្ធសាសនាចុះខ្សោយទេ ប៉ុន្តែផ្ទុយទៅវិញ អ្នកប្រព្រឹត្តអំពើនេះនឹងអស់តម្លៃខ្លួនឯងទៅវិញទេ ព្រោះខ្លួនត្រូវគេវិនិច្ឆ័យថា ជាមនុស្សអាក្រក់ ដោយហេតុតែបានបៀតបៀនសាសនាដទៃ ។ ពិតមែនតែសហរដ្ឋអាមេរិកមានសេរីភាពខាងការផលិតនិងការផ្សាយកុនក៏ដោយ ប៉ុន្តែរដ្ឋាភិបាលសហរដ្ឋអាមេរិក អាចហាមឃាត់នូវកុនណា ដែលធ្វើឲ្យចលាចលខូចប្រយោជន៍សង្គមអាមេរិក ដូចសហរដ្ឋអាមេរិកឲ្យក្រុមហ៊ុនដកហូតយករូបព្រះពុទ្ធចេញពីកុននោះជាដើម ។ លទ្ធផលជាវិជ្ជមាននេះ កើតឡើងដោយការប្រឆាំងយ៉ាងខ្លាំងក្លាពីសំណាក់អ្នកកាន់ព្រះពុទ្ធសាសនាសកលលោក មានប្រទេសកម្ពុជា ប្រទេសស្រីលង្កា ប្រទេសថៃជាដើម ។ តួឯកកុននេះគប្បីគតិថា បើមានជនណាម្នាក់យករូបមេបង្កើតសាសនារបស់ខ្លួន ទៅអង្គុយពីលើក្បាលដូចគ្នានេះ ខ្លួនពិតជាមានប្រតិកម្មតបវិញដូចនេះដែរ ។ ខ្លួនអាចប្រើសិទ្ធិរបស់ខ្លួន ប៉ុន្តែកុំឲ្យប៉ះសិទ្ធិអ្នកដទៃ ក៏ដូចជាពុទ្ធសុភាសិតពោលថា បើខ្លួនចង់បានសេចក្តីសុខ មិនត្រូវបៀតពៀនអ្នកដទៃឡើយ ព្រោះសេចក្តីសុខកើតមកអំពីការមិនបៀតពៀនគ្នាទៅវិញទេ ។ ចំពោះប្រទេសកម្ពុជាដោយសារព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដូច្នេះរដ្ឋត្រូវតែបំពេញមុខនាទីរបស់ខ្លួន ដោយប្រឆាំងតបវិញចំពោះជនណាដែលប្រមាថមើលងាយព្រះពុទ្ធសាសនា ។ ព្រឹត្តិការណ៍នេះកើតឡើង រឹតតែធ្វើឲ្យអ្នកកាន់ព្រះពុទ្ធសាសនាក្នុងសកលលោករួមសាមគ្គីគ្នា កាន់តែរឹងមាំឡើង ដើម្បីរក្សាការពារព្រះពុទ្ធសាសនា ឲ្យបានគង់វង់ ទុកជាមាគ៌ាសន្តិភាពក្នុងប្រទេសរៀងខ្លួននិងសន្តិភាពសកលលោក ។

២- **ការចុះបញ្ជីឆ្នោត ដោយពុំបានអនុវត្តក្រសួងអន្តោប្រវេសន៍** ៖

ប្រជាពលរដ្ឋខ្មែរទាំងក្នុងប្រទេសនិងក្រៅប្រទេស មានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះវាសនាប្រទេសរបស់ខ្លួន ដែលមានជនជាតិវៀតណាមរស់នៅខុសច្បាប់នៅប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៧៩មក ដោយពុំមានក្រសួងអន្តោប្រវេសន៍ពិនិត្យថា តើជនជាតិវៀតណាមរស់នៅស្របច្បាប់ប៉ុន្មាននាក់ ពុំស្របច្បាប់ប៉ុន្មាននាក់ទេ ។ មិនតែប៉ុណ្ណោះក្រសួងមហាផ្ទៃខ្មែរ បានអនុញ្ញាតឲ្យជនជាតិវៀតណាម ដែលរស់នៅក្នុងខេត្ត១៩ បង្កើតសមាគម ដើម្បីការពារជនជាតិគេ ។ ការអនុញ្ញាតច្បាប់នេះ ទុកជាការសម្រួលច្បាប់ឲ្យជនជាតិវៀតណាមដែលរស់នៅខុសច្បាប់ ។ សព្វថ្ងៃនេះ ជនជាតិវៀតណាមបានដណ្តើមការងារខ្មែរធ្វើ ដូចជាជាងសំណង់ ធ្វើការតាមបេនឡាន និងធ្វើការនេសាទតាមដងទន្លេសាបជាដើម ។ រាជរដ្ឋាភិបាលដែលកើតឡើងដោយការបោះឆ្នោតជាកញ្ចប់ និងដោយការលើកដៃ ដោយព្យួរទុកធម្មនុញ្ញឆ្នាំ១៩៩៣នោះ បានព្រមព្រៀងគ្នាថា នឹងបង្កើតក្រសួងអន្តោប្រវេសន៍នៅពេលណាមួយសមស្រប ។ នៅពេលដែលរដ្ឋាភិបាលកញ្ចប់នេះបានកើតឡើងហើយ ពុំទាន់ឃើញក្រសួងនេះបង្កើតឡើងនៅឡើយទេ ។ សូម្បីតែគណបក្សមួយក្នុងរដ្ឋាភិបាលចំរុះ ដែលបានស្នើឲ្យបង្កើតក្រសួងនេះ ស្រាប់តែស្ងាត់មាត់ឈឹង ពេលដែលបានអំណាចហើយ ។ អ្នកខ្លះនិយាយថា ជនជាតិវៀតណាមដែលរស់នៅខុសច្បាប់ក្នុងប្រទេសកម្ពុជាមានចំនួនរាប់លាននាក់ ហើយខ្លះជាចារកិច្ចរបស់វៀតណាមផង ។ បានជាជនជាតិវៀតណាមរស់នៅកាន់តែច្រើនឡើងៗនៅប្រទេសកម្ពុជា មកអំពីខ្មែរយាមព្រំដែនពុំបានអនុវត្តច្បាប់ឲ្យបានតឹងរ៉ឹង មានខ្លះគ្រាន់តែឲ្យដុល្លារបន្តិចបន្តួចដល់អ្នកយាមៗក៏បើកផ្លូវឲ្យចូលមានរហូតដល់ឧបម៉ូតូជូនដំណើរដល់ភ្នំពេញទៀតផង ។ គេនិយាយគ្រប់គ្នាថា ពេលវៀតណាមចូលមកប្រទេសកម្ពុជា គឺគេចូលបានដោយងាយ ប៉ុន្តែបើខ្មែរចូលទៅវៀតណាមវិញ មានការពិបាកណាស់ ក្រៅពីការពិនិត្យសំបុត្រឆ្លងដែន គេតែងពិនិត្យមើលវត្ថុជាប់តាមខ្លួនយ៉ាងហ្មត់ចត់ថែមទៀត ហើយក៏ពុំបានអនុញ្ញាតឲ្យចូលគ្រប់គ្នាឡើយ ។ ជនជាតិខ្មែរពុំមែនប្រកាន់ជាតិសាសន៍ទេ គឺដើម្បីកំណត់ឲ្យដឹងថា បើជនជាតិវៀតណាមណារស់នៅដោយស្របច្បាប់ រដ្ឋត្រូវតែរក្សាការពារជនជាតិវៀតណាមនោះ ដែលរស់នៅប្រទេសកម្ពុជា និងស្របតាមច្បាប់អង្គការសហប្រជាជាតិ ដោយមិនត្រូវប្រើអំពើហឹង្សាឡើយ ។

ឥឡូវនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរៀបចំបញ្ជីឲ្យចុះឈ្មោះបោះឆ្នោត ចំពោះជនជាតិខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ។ ការរៀបចំចុះបញ្ជីបោះឆ្នោត ដោយពុំទាន់បានបង្កើតក្រសួងអន្តោប្រវេសន៍នេះ ជាការព្រួយបារម្ភរបស់ជនជាតិខ្មែរ ថាអាចជនជាតិវៀតណាមដែលរស់នៅខុសច្បាប់ សម្រួលច្បាប់ជាមួយអាជ្ញាធរខ្មែរ ឲ្យមានសិទ្ធិបោះឆ្នោត នោះកម្ពុជានឹងទទួលគ្រោះថ្នាក់ក្នុងបច្ចុប្បន្ននេះនិងទៅអនាគត ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគប្បីពិចារណាឲ្យបានហ្មត់ចត់ចំពោះបញ្ហានេះ ព្រោះត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋខ្មែរ ចំពោះផលវិបាកអាក្រក់ដែលអាចកើតឡើងដូចបានពោលមកហើយ ។ មួយទៀត រដ្ឋសភាខ្មែរនិងអង្គការក្រៅរដ្ឋាភិបាល គប្បីជួយដោះស្រាយបញ្ហានេះឲ្យដល់ជំរៅ ។ ៚